ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ១៧៣៥ ព.ណ....

ថ្ងៃច័ន្ទ ៣កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដល់អ្នកនាំចូលទៅកាន់សហរដ្ឋអាមេរិកពីកម្ពុជាឲ្យបានជ្រាបថា៖ ចំនួនក្រុមហ៊ុន ដែលចុះបញ្ជីទីតាំងផលិតចំណីអាហារ ជាមួយអាជ្ញាធរចំណីអាហារ និងថ្នាំពេទ្យសហរដ្ឋអាមេរិក **[U.S Food and Drug Administration(FDA)]** បានធ្លាក់ចុះចំនួន២០ ភាគរយ រវាងខែធ្នូ ឆ្នាំ២០១៨ និងខែកុម្ភៈ ឆ្នាំ២០១៩ ក្នុងនោះជាពិសេសចំនួនដែលបានចុះបញ្ជីពីប្រទេសកម្ពុជាមានការធ្លាក់ចុះពីចំនួន ៥៦ក្រុមហ៊ុន មក ៣៦ក្រុមហ៊ុន ដែលបណ្តាលមកពី **U.S. FDA** លុបចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ខ្លួន ដោយពុំបានជូនដំណឹងពីការចុះបញ្ជីឡើងវិញឲ្យបានត្រឹមត្រូវកាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

ដើម្បីជៀសវាងនូវការឃាត់ឃាំង ឬ សកម្មភាពនិយ័តកម្មផ្សេងៗ ក្រុមហ៊ុន **Registrar Corp** សហរដ្ឋអាមេរិក នឹងសម្របសម្រួលផ្តល់សេវាផ្ទៀងផ្ទាត់ដោយឥតគិតថ្លៃ ចំពោះការចុះបញ្ជីទីតាំងផលិតចំណីអាហារឡើងវិញសម្រាប់សុពលភាព ឆ្នាំ២០១៩ ជាមួយ **U.S. FDA** ទើបអាចអនុញ្ញាតឲ្យធ្វើការនាំចូល និងចែកចាយនៅសហរដ្ឋអាមេរិកបាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអ្នកនាំចូលទៅកាន់សហរដ្ឋអាមេរិកទាំងអស់ ដែលមានបំណងចុះបញ្ជីទីតាំងផលិតចំណីអាហារជាមួយ **U.S. FDA** ឡើងវិញ សូមធ្វើការទាក់ទងដោយផ្ទាល់ជាមួយក្រុមហ៊ុន **Registrar Corp** តាមរយៈគេហទំព័រ www.registrarcorp.com/verify ឬ លោក **Coley Anderson**, Director of Industry and Government Relation, Office: (757) 224-0177 ext. 357 | Mobile: (757) 285-4568 | canderson@registrarcorp.com ។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម